00882779

002/19-09-2007-ECCC/TC
E1/155

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 01 / 2013
ម៉ោង (Time/Heure): 11:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ចន្ទ ទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៤២

រៀបចំដោយៈ សែ កុលវុឌ្ឍី និង Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ (ជំនួសចៅក្រម Jean-Marc LAVERGNE), ចៅក្រម យូរ ឧត្តរា (មានវត្តមានតែសវនាការវគ្គទី១), ចៅក្រម ធូ មណី (ជំនួសចៅក្រម យូរ ឧត្តរា ចាប់ពីសវនាការវគ្គទី២) |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី (នៅក្នុងសវនាការវគ្គទី១) |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត, លោក Keith RAYNOR. |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន, អៀង សារី (ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក ពេជ អង្គ, លោក គីម ម៉េងឃី, លោកស្រី ស៊ិន សុវន, លោក ហុង គីមសួន, លោក ឡោ ជុនធី |
| សាក្សី៖ លោក សួន កានិល ហៅ នាង (TCW-695) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា Eleanor DOYLE-MARKWICK |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០៧ | បញ្ចប់ម៉ោង៖ ១១.៥៦ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣២ | បញ្ចប់ម៉ោង៖ ១០.៥៦ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០២ ម៉ោង និង ៣០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សមាសភាពចៅក្រមជំនុំជម្រះសម្រាប់សវនាការថ្ងៃនេះ | អង្គជំនុំជម្រះ | ០៩.១០<br>១០.៥៦ | ០៩.១០<br>១០.៥៧ |
| ការស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្តី នួន ជា | ០៩.១០ | ០៩.១៣ |
| ការបន្តតាំងសំណួរទៅសាក្សី សួន កានិល (TCW-695) | សហព្រះរាជអាជ្ញា<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.១៣<br>០៩.៥៩<br><br>១០.៥៧<br>១១.៤០<br>១១.៤២ | ០៩.៥៨<br>១០.៣២<br><br>១១.៣៩<br>១១.៤២<br>១១.៤៨ |
| កាលបរិច្ឆេទសម្រាប់ស្តាប់សក្ខីកម្មសាក្សីសម្រាប់សប្តាហ៍ដែលនៅសល់ | អង្គជំនុំជម្រះ | ១១.៤៨ | ១១.៥៦ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**សមាសភាពរបស់ចៅក្រមជំនុំជម្រះសម្រាប់សវនាការថ្ងៃនេះ**

ប្រធានអង្គជំនុំជម្រះបានជូនដំណឹងទៅភាគីថា លោកស្រី ចៅក្រម Claudia FENZ នឹងជំនួសលោកចៅក្រម Jean-Marc LAVERGNE ដែលមានបញ្ហាសុខភាពមិនអាចចូលរួមសវនាការបាន និងលោកចៅក្រម ធូ មណី និងជំនួស លោកចៅក្រម យូរ ឧត្តរា ដោយមូលហេតុសុខភាព ចាប់ពីសវនាការវគ្គទី២នេះទៅ។

**ការបន្តតាំងសំណួរទៅសាក្សី សួន កានិល (TCW-695)**

សហព្រះរាជអាជ្ញាបានបន្តតាំងសំណួរទៅសាក្សី សួន កានិល បន្ទាប់មកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចាប់ផ្តើមតាំងសំណួរ។ ក្រុមមេធាវីការពារក្តី នួន ជា អៀង សារី និង ខៀវ សំផន បានតាំងសំណួរ និងបញ្ចប់ការតាំងសំណួរទៅសាក្សី សួន កានិល។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ នួនជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់សម្រាប់រយៈពេលពេញមួយថ្ងៃដោយមូលហេតុសុខភាព។ អង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំ។

**កាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មសាក្សីសម្រាប់សប្តាហ៍ដែលនៅសល់**

សាក្សី ស វី (TCW-620) ដែលបានកោះហៅមកផ្តល់សក្ខីកម្មសម្រាប់សវនាការនៅពេលរសៀល និងថ្ងៃបន្តបន្ទាប់ទៀត បានជួបគ្រោះថ្នាក់ចរាចរណ៍ ដែលមិនអាចមកផ្តល់សក្ខីកម្មបាន។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានកំពុងព្យាយាមរកសាក្សី ផ្សេងទៀតដែលអាចមានលទ្ធភាពមកផ្តល់សក្ខីកម្មនៅក្នុងសប្តាហ៍នេះបាន។ ប្រសិនបើអង្គភាពគាំពារសាក្សី និងអ្នកជំនាញ អាចរកសាក្សីបាន អង្គជំនុំជម្រះនឹងបន្តសវនាការនៅក្នុងសប្តាហ៍នេះ។ អង្គជំនុំជម្រះនឹងជូនដំណឹងទៅភាគីតាមរយៈសារអេឡិចត្រូនិចយ៉ាងយូរបំផុតនៅព្រឹកថ្ងៃស្អែក។ បន្ទាប់មកភាគីត្រូវបានជូនដំណឹងតាមរយៈសារអេឡិចត្រូនិចដែលបញ្ជាក់ថាមិនមានសាក្សីដែលអាចមកផ្តល់សក្ខីកម្មបាននៅក្នុងអំឡុងពេលនេះទេ ហេតុដូច្នេះអង្គជំនុំជម្រះពន្យារសវនាការ រហូតដល់ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/411 | D232/9 | 00373506-00373517 00390073-00390082 00424032-00424044 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល SUON Kanil ថ្ងៃទី ១៩-០៨-២០០៩ [Corrected 1] Written Record of Interview of SUON Kanil សួន កានិល dated 19-08-2009 Procès verbal d'audition de témoin SUON Kanil សួន កានិល dated 19-08-2009 | P | 00373507, 00373516 | 00390074-75, 00424082 | 00424033, 00424043 |
| E3/344 | D232/8 | 00373490-00373505 00384422-00384435 00426140-00426156 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល SUON Kanil ថ្ងៃទី ១៨-០៨-២០០៩ [Corrected 1] Written Record of Interview of SUON Kanil សួន កានិល dated 18-08-2009 [Corrigé 1] Procès verbal d'audition de témoin SUON Kanil សួន កានិល dated 18-08-2009 | P | 00373503 | 00384434 | 00426154 |
| E3/1679 | D200/3.1 | 00008494-00008494 00766762-00766763 00766748-00766749 | ទូរលេខ ១៥ ស្តីពី៖ សូមជំរាបជូន បង ប៉ុល ជាទីគោរព Telegram 15 entitled "Respectfully submitted to comrade Brother Pol" Télégramme 15 intitulé "À l'attention du cher camarade Bang Pol" | P | | | |
| E3/511 | D175/6.20 | 00000766-00000767 00182658-00182660 00350762-00350763 | ទូរលេខលេខ ៩៤ ជូនបង ប៉ុល: រាយការណ៍ជូនបងពីសភាពការណ៍ខ្មាំង, មហាជន និងបង្ករបង្កើតផល នៅភូមិភាគឧត្តរ Telegram # 94 to brother Pol: Report to Brother about enemy, people and production situation in north region. Télégramme: 44 A l'attention du respecté Bang Pol à propos de la situation des ennemis, celle de la population et de la production générale dans la Zone Nord | P | | | |
| E3/3978 | D22/3451 | 00565828-005658390 0849874-00849875 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី ហ៊ឹម LI Him 09-VU-03800 [Partial T.] Demande de constitution de partie civile de LIM Him 09-VU-03800 | P | 00565834 | | 00849874 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| E3/932 | 21.10 9 | 00020998-00020999 00185199-00185200 00392536-00392537 | ទូរលេខ ០២៖ សូមជំរាបមក គណៈ ៨៧០ ជាទីស្នេហា និងរលឹក អំពីសភាពការណ៍សមរភូមិផ្លូវលេខ ៧ Telegram 02 : To respected committee 870: About situation of the battlefield around Road Number 7 Telegram 02 : To respected committee 870: About situation of the battlefield around Road Number 7 | P | | | | |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឱ្យជនជាប់ចោទ នួន ជា (០៩.១៣) ចូលរួមដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួន (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនសាក្សី សួន កានិល (TCW-695) ត្រឡប់ទៅកាន់គេហដ្ឋានរបស់គាត់វិញ ដោយសក្ខីកម្មរបស់សាក្សីរូបនេះបានចប់ជាស្ថាពរ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ខៀវ សំផន និង អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញចុះ។

**កាលបរិច្ឆេទបន្តសវនាការ៖**

សវនាការត្រូវបានពន្យារពេលរហូតដល់អង្គជំនុំជម្រះអាចរកបានសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលអាចមកផ្តល់សក្ខីកម្មបាននៅក្នុងសប្តាហ៍នេះ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២

ក្រឡាបញ្ជី ... ក្រឡាបញ្ជី

សេ [illegible] Roger PHILLIPS

For